បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE

# ព្រះត្រៃបិដកជាភាសាខ្មែរ

ភ្នំពេញ
ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ
ព.ស ២៥៣៩

២១១.
១

# ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត

ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីស្ស៊ូ កូស៊ី-កៃ  វិទ្យាស្ថានបើកទូលាយ**

**ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh    www.elibraryofcambodia.org

២១១.២

# ព្រះត្រៃបិដកជាភាសាខ្មែរ

បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE
១១៤៤/៩៥
05-12

រៀបរៀងដោយ
ព្រះវិរិយបណ្ឌិតោ **ប៉ាង ខាត់**
វត្តឧណ្ណាលោម ភ្នំពេញ

បោះពុម្ពឡើងវិញ ចំនួន ៥០០០ ច្បាប់
ដោយថតចម្លងតាមច្បាប់បោះពុម្ព ឆ្នាំ ១៩៧០

ភ្នំពេញ
ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ
ព.ស ២៥៣៨ គ.ស១៩៩៥

## សេចក្តីបញ្ជាក់អំពីការបោះពុម្ពឡើងវិញ
## នៃសៀវភៅព្រះត្រៃបិដកជាភាសាខ្មែរ

សៀវភៅឈ្មោះ " ព្រះត្រៃបិដកជាភាសាខ្មែរ " នេះ ជាស្នាព្រះហស្តរបស់ព្រះតេជព្រះគុណព្រះមហាវិរិយបណ្ឌិតោ « ប៉ាង ខាត់ » ដែលជាសាស្ត្រាចារ្យដ៏ល្បីល្បាញមួយអង្គនៅមុនឆ្នាំ ១៩៧៥ ។ សៀវភៅព្រះត្រៃបិដកជាភាសាខ្មែរ ជាអត្ថបទសង្ខេបស្តីអំពីគម្ពីរព្រះត្រៃបិដក ដែលជាគម្ពីរមូលដ្ឋានគ្រឹះនៃព្រះពុទ្ធសាសនា ជាឃ្លាំងផ្ទុកនូវពុទ្ធវចនៈទាំង ៨ ម៉ឺន ៤ពាន់ព្រះធម្មខន្ធ ហើយដែលអ្នកប្រាជ្ញខ្មែរខាងពុទ្ធសាសនា បានខិតខំបកប្រែពីភាសាបាលីមកជាភាសាខ្មែរ ព្រមទាំងបោះពុម្ពផ្សាយចាប់តាំងពីឆ្នាំ ១៩២៩ រហូតដល់ឆ្នាំ ១៩៦៩ ទើបចប់សព្វគ្រប់ ។ នៅមុនឆ្នាំ ១៩៧០ អត្ថបទនេះ ត្រូវបានគេបោះពុម្ពផ្សាយពីរលើករួចមកហើយ គឺលើកទីមួយ អត្ថបទដ៏សំខាន់នេះ ត្រូវបានគេចុះផ្សាយក្នុងទស្សនាវដ្តីខេមរ-យានកម្ម លេខ ៧ ឆ្នាំ ១៩៦៩, លើកទីពីរ ត្រូវបានលោក លាង ហ៊បអាន នាយកពុទ្ធសាសន-បណ្ឌិត្យ បោះពុម្ពដើម្បីចែកជាធម្មទានក្នុងឱកាសព្រះរាជពិធីបុណ្យព្រះបរមសពនៃសម្តេចព្រះមហាសុមេធាធិបតី ព្រះនាម ជួន ណាត ជោតញ្ញាណោ ព្រះសង្ឃរាជថ្នាក់ទី ១ គណៈមហានិកាយ កាលពីឆ្នាំ ១៩៧០ ។

ដោយយល់ឃើញថា ម្យ៉ាងសៀវភៅព្រះត្រៃបិដកជាភាសាខ្មែរនេះ មានសារ-សំខាន់ដល់អ្នកសិក្សា ស្រាវជ្រាវអំពីប្រវត្តិនៃគម្ពីរព្រះត្រៃបិដក ក៏ដូចជាដល់ការស្វែងយល់អំពីព្រះពុទ្ធសាសនា និងម្យ៉ាងទៀត ដើម្បីអបអរសាទរចំពោះការបោះពុម្ពឡើងវិញនៃគម្ពីរព្រះត្រៃបិដកជាភាសាខ្មែរចំនួន ១.០០០ ចប់ ដែលជាជំនួយដ៏សប្បុរសរបស់ពុទ្ធសាសនិកជប៉ុន ទើបពុទ្ធសាសនបណ្ឌិត្យ សម្រេចចាត់ចែងបោះពុម្ពសៀវភៅព្រះត្រៃបិដកជាភាសាខ្មែរនេះឡើងវិញ ដើម្បីចែកជាធម្មទានក្នុងឱកាសបុណ្យទទួលគម្ពីរព្រះត្រៃបិដក ចំនួន ១.០០០ ចប់ ដែលនឹងប្រព្រឹត្តទៅយ៉ាងឱឡារិក នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៩៥ នេះ ។

ការបោះពុម្ពលើកទី ៣ នេះ ដែលមានចំនួន ៥.០០០ ច្បាប់ មិនអាចសម្រេចទៅបានឡើយ បើគ្មានការជួយឧបត្ថម្ភខាងថវិការបស់អង្គការជំនួយសូត្ត្រស៊ូជប៉ុន (JSRC) និងអង្គការជប៉ុន ឈ្មោះរិស្សូ កូសី-កៃ (RKK) ។

ពុទ្ធសាសនបណ្ឌិត្យ ឆ្លៀតយកឱកាសដ៏ប្រសើរថ្លៃថ្លានេះ សូមថ្លែងនូវកតញ្ញុតា-ធម៌ដ៏ជ្រាលជ្រៅចំពោះអង្គការជំនួយសូត្តស៊ូជប៉ុន និងអង្គការរិស្សូកូសី-កៃ និងសូមឧទ្ទិសផ្គួមនុញ្ញផល និងមហាកុសល ដែលកើតអំពីការបោះពុម្ពផ្សាយនៃសៀវភៅព្រះត្រៃបិដកជាភាសាខ្មែរនេះ ថ្វាយចំពោះព្រះករុណាជាម្ចាស់ជីវិតម្កល់លើត្បូង ព្រះបាទសម្ដេចព្រះនរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងសម្ដេចព្រះមហេសីនរោត្តម មុនីនាថ សីហនុ សូមព្រះអង្គប្រកបដោយព្រះសុខុមាលភាពបរិបូណ៌ និងមានព្រះជន្មាយឺនយូរជាងរយព្រះវស្សា ដើម្បីទ្រង់គង់ជាម្លប់ដ៏ត្រជាក់សម្រាប់ប្រជាពលរដ្ឋកម្ពុជា អស់កាលជាអង្វែងតទៅ ។

សូមប្រគេនព្រះមហាកុសលដែលកើតពីធម្មទាននេះ ចំពោះព្រះវិញ្ញាណក្ខន្ធរបស់ព្រះតេជព្រះគុណព្រះមហាវិរិយបណ្ឌិតោ ប៉ាង ខាត់ ដែលជាអ្នកនិពន្ធសៀវភៅនេះ សូមព្រះអង្គបានទៅសោយសុខនៅសុគតិភព ជានិរន្តរ៍តរៀងទៅ ។

ភ្នំពេញ, ថ្ងៃទី ២៥ មេសា ១៩៩៥

ពុទ្ធសាសនបណ្ឌិត្យ

## ごあいさつ

この本は、立正佼成会と曹洞宗国際ボランティア会との共同プロジェクトとして印刷されました。

この本が、日本の仏教徒とカンボジアの人々との友情のきずなとなり、カンボジアの文化発展に貢献できれば幸いです。

## និវេទនកថា

សៀវភៅនេះ ត្រូវបានបោះពុម្ពឡើងវិញ ដោយគណៈកម្មាធិការជំនួយសូតូស៊ូជប៉ុន (JSRC) នៅភ្នំពេញ ដោយមានការឧបត្ថម្ភពី

អង្គការ រិស្សូ កូសី-កៃ

យើងខ្ញុំអធិដ្ឋាន សូមអោយសៀវភៅនេះ បានជាវិភាគទានរក្សាមិត្តភាពជាមួយប្រជាជនកម្ពុជា និងថែរក្សាសម្បត្តិសាសនា និងសម្បត្តិវប្បធម៌របស់ប្រជាជនកម្ពុជា ។

## Acknowledgement

This book has been printed by Japan Sotoshu Relief Committee ( JSRC ) with the contribution from

RISSHO KOSEI-KAI

We pray that this book would contribute to the friendship with Cambodian people and their religious and cultural preservation.

# ព្រះត្រៃបិដកជាភាសាខ្មែរ

## លាង - ហ័បអាន

**ចាត់ចែងបោះពុម្ពចែកជាធម្មទាន**

ក្នុងឱកាសព្រះរាជពិធីបុណ្យ ព្រះបរមសព

សម្តេចព្រះមហាសុមេធាធិបតីទ្រង់ព្រះនាម

ជួន-ណាត ជោតញ្ញាណោ

ព្រះសង្ឃរាជ ថ្នាក់ទី ១ គណៈមហានិកាយ

ដោយសេចក្តីយល់ព្រមពីគណៈកម្មការរងខាងឃោសនា

គណៈកម្មាធិការរៀបចំពិធីបុណ្យ

# ព្រះត្រៃបិដកជាភាសាខ្មែរ

រៀបរៀងដោយ
ព្រះវីរិយបណ្ឌិតោ ជ៉ាង ខាត់

វត្តឧណ្ណាលោម ភ្នំពេញ

ព.ស. ២៥១៤ គ.ស. ១៩៧០



សម្តេចព្រះមហាសុមេធាធិបតីព្រះនាម ជួន ណាត

ព្រះសង្ឃរាជ គណៈមហានិកាយ



ឡាង ហ័ប អាន

បច្ចុប្បន្ននាយកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ

ក្រសួងធម្មការ



អ្នកស្រី លាង ហ័ប អាន
នាមដើម ព្រាញ នាង សៀង
( អគ្គលេខាធិការរងនៃវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ )

## សេចក្តីប្រារព្ធរបស់អ្នកបោះពុម្ពចែកជាធម្មទាន

សម្តេចព្រះសង្ឃរាជជាអម្ចាស់ កាលទ្រង់គង់ព្រះជន្មាយុនៅឡើយ ទ្រង់សព្វព្រះរាជហឫទ័យនឹងអត្ថបទឈ្មោះ "ព្រះត្រៃបិដកជាភាសាខ្មែរ" ជាស្នាព្រះហស្តរបស់ព្រះតេជព្រះគុណព្រះមហាវីរិយបណ្ឌិតោ "**ប៉ាំង-ខាត់**" ដែលជាគ្រូរបស់ខ្ញុំ ៗ អត្ថបទនេះ ចុះផ្សាយម្តងរួចទៅហើយក្នុងទស្សនាវដ្តី ខេមរ–យានកម្ម លេខ ៧ ឆ្នាំ ១៩៦៩ ដែលទ្រង់ព្រះរាជបំណាននូវការពេញព្រះរាជហឫទ័យ ចង់ឲ្យឯកសារដ៏មានប្រយោជន៍នេះ បានឡើងទៅជាសៀវភៅសម្រាប់ផ្សាយចំពោះសាធារណជនជាពុទ្ធបរិស័ទ ៗ ខ្ញុំបានទទួលព្រះបរមរាជបញ្ញាតាមព្រះចំណាននេះហើយ ក៏ប្រញាប់ប្រញាល់ធ្វើលិខិត(លេខ ៨២៨ ព.ប ចុះថ្ងៃ ២ តុលា ១៩៦៩) ដើម្បីសុំសិទ្ធិបោះពុម្ពផ្សាយជាបឋមចែកជាធម្មទានក្នុងឱកាសបុណ្យថ្វាយព្រះភ្លើង ព្រះបរមសពនៃសម្តេចព្រះសង្ឃរាជជាអម្ចាស់ ហើយតទៅ នឹងបោះពុម្ពផ្សាយជាជូនពុទ្ធបរិស័ទ ដោយទុកអត្ថបទនេះជាសម្បត្តិរបស់រដ្ឋ គឺរបស់វិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ ៗ

សហជីវិន **ហង្ស ធុនហាក់** សកលវិទ្យាធិការសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈនិងជាប្រធានគណៈកម្មាធិការជាតិនៃខេមរយានកម្មសិក្សា ក៏មានសប្បុរសធម៌ ឆ្លើយតប យល់ព្រមតាមការសុំរបស់វិជ្ជាឋានភ្លាម តាមលិខិតរបស់សហជីវិនលេខ ៨៨២ អ ខ ស ចុះថ្ងៃ ៤ តុលា ១៩៦៩ ៗ

ដោយបានសម្រេចនូវការសុំសិទ្ធិផ្សាយនេះ ខ្ញុំក៏បាននាំអត្ថបទនេះទៅសុំព្រះតេជព្រះគុណព្រះមហាវីរិយបណ្ឌិតោ ព្រះអង្គពិនិត្យផ្ទៀងផ្ទាត់កែសម្រួលជាថ្មីឲ្យកាន់តែវិសេសឡើង ។ ក្នុងការផ្សាយជាបឋមនេះ ខ្ញុំមានសទ្ធាបោះពុម្ពនូវស្នាព្រះហស្តនេះចំនួន ៥ ពាន់ច្បាប់ ដើម្បីចែកជាធម្មទានក្នុងឱកាសថ្វាយព្រះភ្លើងព្រះបរមសពនៃសម្តេចព្រះសង្ឃរាជដែលព្រះអង្គមានព្រះមហាករុណាធិគុណដ៏ធំ ចំពោះវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ ក៏ដូចជាចំពោះរូបខ្ញុំផ្ទាល់ ។

ខ្ញុំសូមលើកយកកុសលដែលកើតមកអំពីធម្មទាននេះ ថ្វាយចំពោះព្រះវិញ្ញាណក្ខន្ធ នៃសម្តេចព្រះសង្ឃរាជជាអម្ចាស់ សូមព្រះអង្គបានសោយនូវសម្បត្តិព្រះនិព្វានជាបរិយោសាន ។ សូមឧទ្ទិសព្រះរាជកុសលផលបុណ្យនេះប្រគេនចំពោះសម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយក ព្រះនាម “ហួត តាត” ជាអម្ចាស់ដែលព្រះអង្គមានព្រះគុណធ្ងន់ណាស់ចំពោះខ្ញុំដែលបានមកបម្រើព្រះអង្គគម្រប់១៤ឆ្នាំហើយ សូមសម្តេចទ្រង់បានប្រកបដោយបរមសុខ ព្រះជន្មាយុយឺនយូរ ជាទីកក់ក្តៅនៃវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ និងដូនពុទ្ធបរិស័ទក្នុងកម្ពុជរដ្ឋទាំងមូល ។

មួយចំណែកទៀត សូមឧទ្ទិសផលបុណ្យដែលកើតមកអំពីធម្មទាននេះចំពោះវិញ្ញាណក្ខន្ធនៃបុព្វបុរសរបស់យើងខ្ញុំ មានលោកតា **តាំង ហ៊ិន** លោកតា **យ៉ៅ តាម**, លោកតា **សាខ** , លោកយាយ **ចោខ** , លោកយាយ **ចាយហួយ** , លោក **យ៉ាគិមហុខ** ជាដើម សូមវិញ្ញាណក្ខន្ធអស់លោកតាលោកយាយបានលុះ

សុគតិភព សម្រេចនូវសម្បត្តិព្រះនិព្វានជាទីបំផុត ។ ខ្ញុំសូមលើកយកកុសលរាសីជាបញ្ចប់ ឧទ្ទិសជូនលោកម្ដាយនិងឪពុកទាំងសងខាង មានលោកតា **ឈាង ម៉ូច** លោកតាព្រាប **ជាងឆិង** លោកយាយ **យ៉ា គិមលុន** សូមលោកអ្នកដ៏មានគុណ បានសម្រេចនូវសម្បត្តិសួគ៌សម្បត្តិនិព្វាន តាមសេចក្ដីប្រាថ្នាកុំបីឃ្លៀងឃ្លាត ។

ភ្នំពេញ ថ្ងៃទី ១២ ធ្នូ ១៩៦៩

**ឈាង ហ៊បអាង**

នាយកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យនិងជានាយកការិយាល័យក្រសួងធម្មការ

# បុព្វកថា

ហេតុអ្វីបានជាសៀវភៅ " ព្រះត្រៃបិដកជាភាសាខ្មែរ" ត្រូវបោះផ្សាយក្នុងឱកាសថ្វាយព្រះភ្លើងព្រះបរមសពសម្ដេចព្រះសង្ឃរាជថ្នាក់ទី ១?

ពីថ្ងៃទី ២៩ ឧសភា ១៩៦៩ សម្ដេចព្រះសង្ឃរាជថ្នាក់ទី ១ ព្រះនាម **ជួន ណាត** ទ្រង់បានត្រាស់ឲ្យខ្ញុំចូលទៅគាល់ ។ ព្រះអង្គបានឲ្យខ្ញុំពិនិត្យអត្ថបទនេះថា តើនរណាជាអ្នកសរសេរអត្ថបទនេះ ? ។ ខ្ញុំពិនិត្យសំដីនិយាយ ខ្ញុំអាចទាយបានភ្លាម តែពេលនោះខ្ញុំគ្រាន់តែក្រាបបង្គំទូលថា " ចាំទូលព្រះបង្គំដើរសួរគេអ្នកនិពន្ធនេះសិន" ។ សម្ដេចព្រះសង្ឃរាជបានទ្រង់សរសើរស្នាដៃអ្នកនិពន្ធនេះជាអនេកប្បការដូចមានចែង ព្រះរាជចំណារជាភស្តុតាង ភ្ជាប់ក្នុងទីនេះស្រាប់ ។ ព្រះអង្គមានព្រះបន្ទូលថា " លោក **តាម** ឯងទៅរកមើលតើនរណា គេមានសទ្ធាឲ្យគេបោះពុម្ពសៀវភៅនេះឡើង ព្រោះមានសារប្រយោជន៍ណាស់ ហើយអ្នកនិពន្ធនេះ មិនចាក់ដោតសាសនាដទៃ ហើយនិយាយងាយស្ដាប់ផង " ។

ដោយគោរពតាមព្រះរាជបណ្ដាំនេះ ព្រឹកឡើង ខ្ញុំជំរាបសហជីវិន **ឈាង ហ៊ីមរាន** នាយកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ អំពីព្រះរាជបំណងរបស់សម្ដេចព្រះសង្ឃរាជ ។ សហជីវិន **ឈាង ហ៊ីមរាន** ក៏ទាក់ទងនឹងសហជីវិនប្រធាននៃគណៈកម្មាធិការជាតិនៃខេមរយានកម្ម ព្រមទាំងអ្នកនិពន្ធគឺ ព្រះវីរិយបណ្ឌិតោ **ប៉ាង ខាត់** ដើម្បីសុំសិទ្ធិបោះពុម្ពស្នាដៃនេះតាមព្រះរាជបំណង។

សហជីវិនប្រធាននៃគណៈកម្មាធិការខេមរយានកម្មទិងអ្នកនិពន្ធបានអនុញ្ញាតតាម សេចក្ដីស្នើសុំរបស់សហជីវិននាយកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យដូចបំណង ។

ដោយមានបំណងស្របគ្នាដូច្នេះ ក្នុងពេលប្រជុំគណៈកម្មការងខាងឃោសនានិងបោះពុម្ពសៀវភៅចែកជាធម្មទាន ពេលនោះខ្ញុំក៏បានលើកយករឿងនេះមកដាក់បអង្គប្រជុំ ។ គណៈកម្មការងខាងឃោសនានៃពិធីបុណ្យព្រះបរមសពសម្ដេចព្រះសង្ឃរាជ ក៏យល់ព្រមឲ្យផ្សាយសៀវភៅនេះចែកជាធម្មទាន តាមសទ្ធារបស់ពុទ្ធបរិស័ទ ។

ភ្នំពេញ ថ្ងៃទី ១២ ធ្នូ ១៩៦៩

ឌិក-គាម

សំខាន់ណាស់!
ចុះកាលណាត្រៃបិដកប៉ុ!

[illegible]

# ព្រះត្រៃបិដកជាភាសាខ្មែរ

## ខ្មែរបានប្រែព្រះត្រៃបិដកចប់មុនគេ

## ក្នុងចំណោមប្រទេសពុទ្ធសាសនាក្នុងលោក

សាសនាចាស់ៗ សុទ្ធតែមានគម្ពីរដែលស្ដីពីវេទ របស់មេសាសនា ។ គម្ពីរនេះ គេប្រកាន់ទុកជាគម្ពីរស័ក្ដិសិទ្ធិ ស្មើនឹងមេសាសនាដែរ ។

គម្ពីរព្រាហ្មណ៍ឈ្មោះ វេទ គេទុកជា "ស្រុតិ" (ការបានស្ដាប់ឮមក, Révélation) ពីព្រះមហេស្វរ (សិវទេព) ។ គម្ពីរនេះចាស់ជាងគម្ពីរណាបំផុតក្នុងលោក ដែលមនុស្សលោកអាចធ្វើឡើងកើតទៀតបាន តែមិនដែលមានការរៀបរៀង (ផ្ទៀងផ្ទាត់) ពីអតីតកាលទេ ទើបតែមានការរៀបរៀង

ប្រែថា "ការអាន" (Lecture) ។ គម្ពីរនេះមានលក្ខណៈជាច្បាប់សម្រាប់ប្រទេសជាតិច្រើនជាជាងលទ្ធិសាសនា ដោយពិសេសជាច្បាប់សង្គមស្ដីពីគ្រួសារ ឬទ្រព្យមត៌ក ។ បទបញ្ញត្តិដែលមេសាសនានេះតែងតាំងឡើង បានបន្ទាប ត្រូវគេកត់ទុកលើស្លឹកតែខ្លះ លើស្បែកសត្វខ្លះ លើឈើខ្លះ លើថ្មខ្លះ ឬសាក់លើទ្រូងមនុស្សខ្លះ ហើយមានអក្សរខ្លះជាពាក្យកវីនិពន្ធពិរោះ ជាភាសាអារ៉ាប់ដ៏ប្រសើរ ។

[illegible]

# ព្រះរាជជីវប្រវត្តិសង្ខេប

សម្តេចបានទ្រង់ប្រសូតនៅថ្ងៃ អង្គារ ១១ រោច ខែផល្គុន ឆ្នាំ វក "១១ - ៣ – ១៨៨៣" នៅភូមិកំរៀង សង្កាត់គោគោះ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ, បិតានាម ជួន មាតានាម យក់ ។

ព្រះអង្គទ្រង់ព្រះផ្នួសពីខែ ឧសភា ១៨៩៧ នៅវត្តពោធិព្រឹក្សហៅវត្តពោល្យំ សង្កាត់លាំងកែន ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ សម្តេចទ្រង់ចេះអក្សរនិងភាសាសៀម លាវ បារាំង អង់គ្លេស និង យៀកណាម ។

ព្រះអង្គជាបណ្ឌិតអក្សរសាស្ត្រ ជាព្រះអគ្គនិពន្ធអក្សរសាស្ត្រខ្មែរ ជាអភិធជមហារដ្ឋគុរុនៃសហភាពភូមា ជាព្រះអគ្គមហាបណ្ឌិតនៃសហភាពភូមា ។

ព្រះអង្គទ្រង់សោយព្រះទិវង្គតនៅថ្ងៃទី២៥ខែកញ្ញា គ.ស. ១៩៦៩ វេលាម៉ោង ២០ និង ២០នាទី ក្នុងព្រះជន្មវស្សា ៨៦ ឆ្នាំ ដែលនាំពុទ្ធសាសនិកជនទូទៅស្រយុតស្រយង់ចិត្ត ស្ថិតនៅក្នុងអន្ទង់ទុក្ខារម្មណ៍ពាំនូវសេចក្តីវិយោគយ៉ាងធ្ងន់ក្រៃលែងធ្ងន់ ។

# ព្រះត្រៃបិដកជាភាសាខ្មែរ

## ខ្មែរបានប្រែព្រះត្រៃបិដកចប់មុនគេក្នុងចំណោម ប្រទេសពុទ្ធសាសនាក្នុងលោក

សាសនាធំ ៗ សុទ្ធតែមានគម្ពីរ ដែលស្ដីពីវេទៈរបស់មេសាសនា ។ គម្ពីរនេះ គេប្រកាន់ទុកជាគម្ពីរស័ក្តិសិទ្ធ ស្មើនឹងមេសាសនាដែរ ។

គម្ពីរព្រាហ្មណ៍ឈ្មោះ វេទ គេទុកជា “ស្រុតិ”(ការបានស្តាប់ឮមក= Révélation ) ពីព្រះមហេស្វរ ( អាទិទេព ) ។ គម្ពីរនេះ ចាស់បរមបូរាណបំផុតក្នុងលោក ដែលមនុស្សលោកអាចធ្វើឲ្យកើតឡើងបាន តែមិនដែលមានការរៀបចំ ( ផ្ទៀងផ្ទាត់ ) ពីអតីតកាលទេ ទើបតែមានការរៀបចំក្នុងពេលដែលគម្ពីរនេះ មានការប្រែប្រួល ក្រោមជាលើ លើជាក្រោមទៅហើយ ប្រមាណជា ៧០០ ឆ្នាំកន្លងទៅនេះ ។

គម្ពីរគ្រិស្តឈ្មោះ ប៊ីប ( Bible ) ។ គម្ពីរនេះ ក្រោយមរណកាលព្រះយេស៊ូគ្រិស្ត គេមិនទាន់បានរៀបចំចងក្រងជាគម្ពីរមួយនៅឡើយទេ តមកយូរបន្តិច ទើបមានសាវ័ករៀបចំចងក្រងទុកជាគម្ពីរ ហើយមានការបន្ថែមបន្ថយច្រើន មិនគង់វង្សនៅត្រង់តាមដើមតាំងស្រុងទេ ។ គម្ពីរ ប៊ីប នេះទៀតក៏ជា “ Révélation ” ( ការបានឮមក ) ពីព្រះអាទិទេពដែរ ។

គម្ពីរឥស្លាមឈ្មោះ គួរ-អាន ( Qor An ) ប្រែថា “ ការអាន ”

(Lecture ) ។ គម្ពីរនេះ មានលក្ខណៈជាច្បាប់សម្រាប់ប្រទេសជាតិ ច្រើនផង ជាផ្លូវលទ្ធិសាសនា ដោយពិសេស ជាច្បាប់សង្គមស្ដីពីគ្រួសារ ឬទ្រព្យមត៌ក ។ បទបញ្ញត្តិដែលមេសាសនានេះ តែងតាំងឡើង បានបង្គាប់ឲ្យចារឹកទុកលើស្លឹករឹតខ្លះ លើស្បែកសត្វខ្លះ លើឈើខ្លះ លើថ្មខ្លះ ឬសាក់លើខ្លួនមនុស្សខ្លះ ហើយមានអត្ថបទខ្លះ ជាកាព្យនៃកវីនិពន្ធដ៏ពិរោះ ជាភាសាអារ៉ាប់ដ៏ប្រសើរ ។

គម្ពីរលទ្ធិសាសនាជាពាហ៍សាសនាទាំង៣ខាងលើនេះ ជាវចនៈនៃព្រះអាទិទេព (មហេគួរ ) មិនមែនជារបស់មនុស្សលោកតែងទេ ហើយមិនមែនជាគម្ពីរច្រើនសៀវភៅទេ មានចំនួនតិចណាស់ បើប្រៀបធៀបនឹងគម្ពីរព្រះត្រៃ-បិដកជារបស់ពុទ្ធសាសនា ។

## ព្រះត្រៃបិដក

ក្នុងព្រះពុទ្ធសាសនា គម្ពីរព្រះត្រៃបិដក ជាឃ្លាំងផ្ទុកព្រះពុទ្ធវចនៈ គឺវចនៈនៃអង្គព្រះសម្ពុទ្ធ ( Pensée du Bouddha ) ដែលទ្រង់ទេសនាទូន្មានអស់៤៥វស្សា ចាប់តាំងពីទ្រង់បានត្រាស់ដឹងព្រះសម្មាសម្ពោធិញ្ញាណរហូតមកដល់ទ្រង់បរិនិព្វាន ។ វចនៈដែលទ្រង់សំដែងនេះហៅថា ធម្មវិន័យ ដែលព្រះអង្គសំដែងបញ្ញត្ត ( ធម្មោ ច វិនយោ ច ទេសិតោ បញ្ញត្តោ) ធម្មវិន័យនេះ មាន ៣ ចំណែកគឺ សុត្តន្ត វិន័យ អភិធម្ម ទាំង ៣នេះ ព្រះថេរទាំងឡាយបានសង្គាយនា ( ផ្ទៀងផ្ទាត់ ) ចងក្រង

ហើយដាក់ទុកមួយក្រុមៗហៅថា **តិបិដកំ ព្រះត្រៃបិដក** « កញ្ជើបី » (Triple Corbeille) ។ ពាក្យថា « បិដក » នេះ បើប្រែថា « ខ្ទូ ឬ បណ្ណាល័យ » ក៏សឹងតែបានដែរ ។ បើប្រៀបធៀបមើល ឃើញថា គម្ពីរព្រះត្រៃបិដកនេះ មានចំនួនច្រើនជាងគម្ពីរវេទច្រើនណាស់ ច្រើនជាងគម្ពីរបៃប១១ដង ច្រើនជាងគម្ពីរគូរអានជាអនេក ។

គម្ពីរព្រះត្រៃបិដកនេះ បរិសុទ្ធគង់វង្សនៅដូចដើមគ្រប់ប្រការ មានលក្ខណៈជាគម្ពីរសាសនាពេញបរិបូណ៌ ព្រោះមិនមែនជាវចនៈអាទិទេព មិនមែនជាលទ្ធិសាសនា ឬ ពាហិរសាសនាទេ ។ ក្រោយពុទ្ធបរិនិព្វានភ្លាម មានការធ្វើសង្គាយនាផ្ទៀងផ្ទាត់ភ្លាម ធ្វើឲ្យបានគង់វង្សបរិសុទ្ធនៅដូចដើម មិនមានការបន្ថែមបន្ថយ ឬ ធ្វើក្រោមជាលើ លើជាក្រោមទេ ហើយសមប្រើគ្រប់កាលទាំងពួងទៀតផង ។

គម្ពីរព្រះត្រៃបិដកមាន៣ចំណែកគឺ វិនយបិដក (១៣ភាគ) សុត្តន្តបិដក ( ៦៤ភាគ ) និងអភិធម្មបិដក ( ៣៣ភាគ ) ។ គម្ពីរទាំង៣នេះ មានអដ្ឋកថា ដីកា យោជនា ប្រកបទៀតផង ។

**ក–វិនយបិដក** ជាគម្ពីរស្តីពីច្បាប់ក្រឹត្យក្រម ( Discipline ) ដែលអង្គព្រះសម្ពុទ្ធទ្រង់បញ្ញត្ត ទ្រង់អនុញ្ញាត ទុកសម្រាប់ជាផ្លូវប្រតិបត្តិរបស់ ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ។ គម្ពីរវិន័យនេះ មានសេចក្តីពិស្តារណាស់ ជា

កញ្ចក់ឆ្លុះមើលជីវប្រវត្តិអង្គព្រះសម្ពុទ្ធ ក្នុងកាលដែលទ្រង់គង់ធរមាននៅឡើយ ព្រមទាំងហេតុការណ៍ផ្សេង ៗ នៅប្រទេសឥណ្ឌាសម័យព្រះអង្គ ដូចប្រវត្តិ-សាស្ត្រ ទំនៀមទម្លាប់ ការរចនា និងវិទ្យាសាស្ត្រផ្សេងៗ ។ល។

វិនយបិដកនេះ មាន ៥ គម្ពីរ គឺ

១_អាទិកម្ម (ទោសធ្ងន់) } វិភង្គ
២_បាចិត្តិយ (ទោសស្រាល)

៣_មហាវគ្គ (វគ្គធំ) } ខន្ធក
៤_ចុល្លវគ្គ (វគ្គតូច)

៥_បរិវារ (បទពាយរង)

២_សុត្តន្តបិដក ជាគម្ពីរស្ដីពីសូត្រ ( Aphorisme ) ដែលអង្គព្រះសម្ពុទ្ធទ្រង់ត្រាស់ទេសនាក្នុងសម័យផ្សេងៗ ។ មានសូត្រខ្លះ ព្រះអរិយសាវ័កសំដែង ដូចព្រះសារីបុត្តត្ថេរ ព្រះមោគ្គល្លានត្ថេរ ព្រះអានន្ទត្ថេរ ។ គម្ពីរសុត្តន្ត ឬ គម្ពីរព្រះសូត្រមាន ៥ គម្ពីរ គឺ

១_ទីឃនិកាយ សូត្រមានសេចក្ដីពិស្ដារ

២_មជ្ឈិមនិកាយ សូត្រមានសេចក្ដីមធ្យម

៣_សំយុត្តនិកាយ សូត្រមានសេចក្ដីប្រហែលៗគ្នា

៤_អង្គុត្តរនិកាយ សូត្រមានសេចក្តីជាក្រុមជាពួក

៥_ខុទ្ទកនិកាយ សូត្រមានសេចក្តីខ្លីៗ

ដទៃពីនេះ មាននិកាយតូចៗ តទៅទៀត ចំនួន ១៥ និកាយគឺ

១_ ខុទ្ទកបាឋ អត្ថបទខ្លី

២_ ធម្មបទ ផ្លូវនៃសច្ចធម៌

៣_ ឧទាន គាថាធ្វើឲ្យកើតក្តីរីករាយ

៤_ ឥតិវុត្តក សូត្រដែលស្តីថា "មានដូច្នេះ"

៥_ សុត្តនិបាត សមុច្ច័យនៃសូត្រ

៦_ វិមានវត្ថុ និទានស្តីពីវិមាននៅទេវបុរី

៧_ បេតវត្ថុ និទានស្តីពីប្រេត

៨_ ថេរគាថា គាថាព្រះថេរទេសនា

៩_ ថេរីគាថា គាថាព្រះនាងថេរីទេសនា

១០_ ជាតក និទានជាតក

១១_ និទ្ទេស ការសំដែងពន្យល់

១២_ បដិសម្ភិទា វិជ្ជាវិភាគ

១៣_អបទាន ជីវភាពព្រះអរហន្ត

១៤_ពុទ្ធវំស ប្រវត្តិអង្គព្រះសម្ពុទ្ធ

១៥_ចរិយាបិដក វិធីប្រតិបត្តិតាមពុទ្ធចរិយា

គ_អភិធម្មបិដក ជាគម្ពីរស្តីពីធម៌មានអាថ៌ជ្រាលជ្រៅល្អិតសុខុមបំផុត (Métaphysique) បានដល់ទស្សនវិជ្ជាព្រះសម្ពុទ្ធ ដែលមានអាថ៌គម្ភីរភាព ជាអត្ថបទផ្ទុយពីសុត្តន្តបិដក ដែលមានតែអត្ថបទមានអាថ៌ពក់ៗ គឺសុត្តន្តបិដក ជា វោហារទេសនា (Parole Conventionnelle), ឯអភិធម្មបិដក ជាបរមត្ថទេសនា (Parole definitive) ស្តីពីចិត្ត (conscience) ចេតសិក( Mental concomitant ) រូប ( Matière ) និព្វាន ។ អភិធម្មបិដកនេះព្រះសម្ពុទ្ធទេសនា ទុកជា សត្វទាំងអស់ជា "បុគ្គល ឬ បុគ្គលបញ្ញត្តិ" (concept) ដោយការវែកញែកយ៉ាងល្អិតសុខុម ទាល់តែចែកលែងកើត ហើយចែករំលែកធម៌ ដោយបរិយាយហ្មត់ចត់បំផុត ។ គម្ពីរនេះមានទាំងអស់ ៧ គម្ពីរ គឺ :

១_ធម្មសង្គណី ការចាត់របៀបធម៌

២_វិភង្គ ការចែករំលែកធម៌

៣_កថាវត្ថុ ចំណុចធម៌ដែលមានសេចក្តីផ្ទុយគ្នា

៤_បុគ្គលបញ្ញត្តិ បញ្ញត្តិជា "បុគ្គល"

៥_ធាតុកថា ការវែកញែកធាតុ

៦_យមកៈ ធម៌គូៗគ្នា

៧_បដ្ឋាន ធម៌ជាបច្ច័យទាក់ទងគ្នា

បិដកទាំងបីរួមឈ្មោះថា តិបិដក ឬ ត្រៃបិដក ។ ប្រទេសកម្ពុជាយើង បោះពុម្ពជាសៀវភៅខ្នាតធំមានចំនួន ១១០ សៀវភៅ ជាចំនួនដែលលើសផុតគណនា បើប្រៀបធៀបទៅនឹង ពាហិរសាសនាទាំងអស់ក្នុងលោក ។

## អំពីសង្គាយនា

## សង្គាយនាទីមួយ

ដើម្បីឲ្យបរិសុទ្ធគង់នៅដូចដើម ក្រោយពុទ្ធបរិនិព្វានភ្លាម ព្រះមហាថេរទាំងឡាយចាត់ការធ្វើសង្គាយនាព្រះពុទ្ធវចនៈភ្លាម ដោយហេតុថាសុភទ្ទភិក្ខុធ្វើឲ្យខូចការរៀបរយក្នុងពុទ្ធសាសនា ។ ព្រះអរហន្តជាសង្គីតិកាចារ្យ ៥០០ អង្គ មានព្រះមហា កស្សបត្ថេរ ជាប្រធាន ហើយជាអ្នកសួរ ។ ដើមឡើយសួរវិន័យ ព្រះ ឧបាលិត្ថេរ ជាអ្នកឆ្លើយ តមកសួរធម៌ ព្រះ អានន្ទត្ថេរ ឆ្លើយ សុត្តន្ត និង អភិធម្ម ។ កាលនោះ មិនទាន់មានចារឹកជាលាយលក្ខណ៍អក្សរទេ សួរឆ្លើយយល់ឃើញជាត្រឹមត្រូវហើយ ទើបព្រះអរហន្តទាំង ៥០០ អង្គស្វាធ្យាយគឺសូត្រព្រមគ្នាគ្រប់ទាំង ៥០០អង្គ បងចាំរត់មាត់ស្ទាត់ ។ ការបង

តាំងតែមាត់ទទេបែបនេះ លោកហៅថា មុខបាឋ ។ ធ្វើដូច្នេះ ហៅថា សង្គាយនា ។ សង្គាយនានេះ ធ្វើអស់ថិរវេលា ៧ ខែ ទើបចប់ស្រេច ។

សង្គាយនានេះ ឈ្មោះបឋមសង្គាយនា ធ្វើក្រោយពុទ្ធបរិនិព្វានប្រមាណ ៣ ខែ គឺពុទ្ធសករាជកន្លងទៅបានប្រមាណ ៣ ខែ មុនគ្រិស្តសករាជ៤៧៦(១) ឆ្នាំ ធ្វើនៅក្នុងក្រុងរាជគ្រឹះ លើភ្នំវេភារៈ ត្រង់កន្លែងមួយស្ងាត់ ឈ្មោះ សត្តបណ្ណគុហា ក្រោមការឧបត្ថម្ភព្រះបាទ អជាតសត្រូវ ដែនមគធៈ សព្វថ្ងៃហៅថា រដ្ឋពិហារ ប្រទេសឥណ្ឌា ។

## សង្គាយនាទីពីរ

កាលវេលាកន្លងទៅបាន ១០០ ឆ្នាំ មានកើតការប្រព្រឹត្តិកន្លងពុទ្ធបញ្ញត្តិ ជាហេតុនាំឲ្យសៅហ្មងមណ្ឌលសង្ឃក្នុងពុទ្ធសាសនា ។ ពួកវជ្ជីបុត្ត គឺភិក្ខុជាបព្វជិតកូនចៅអ្នកដែនវជ្ជី ប្រព្រឹត្តកន្លងសិក្ខាបទ ១០ ប្រការ លោកហៅថាវត្ថុ ១០ ប្រការ ។ នេះជាដើមហេតុ នាំឲ្យកើតមានការសង្គាយនាលើកទីពីរឡើង ។ ព្រះ យសត្ថេរ ( កាកណ្ឌបុត្ត ) ប្រកាសការប្រព្រឹត្តិកន្លងវិន័យនេះឲ្យព្រះសង្ឃជ្រាបទូទៅ ។

---

(១) ក្នុងពុទ្ធសាសនា គេរាប់យកថ្ងៃទីមួយ ក្រោយពុទ្ធនិព្វានជាថ្ងៃផ្ដើមពុទ្ធសករាជ ។ ក្នុងលទ្ធិសាសនាគ្រិស្ត គេរាប់យកថ្ងៃកំណើតព្រះយេស៊ូ ជាថ្ងៃផ្ដើមគ្រិស្តសករាជ ។ លទ្ធិសាសនាឥស្លាម គេរាប់យកថ្ងៃព្រះមោហាម៉ែតចូលទៅកាន់ក្រុងយ៉ាត្រិបគឺ ម៉េឌីន (Medina=ក្រុងមុនី) ជាសករាជ ។

សង្គាយនានេះ ធ្វើឡើងនៅក្រោមអធិបតីភាពព្រះ សព្វកាមិត្ថេរ ។ ព្រះរេវតត្ថេរ (សហជាតិ) ជាអ្នកសួរ ព្រះសព្វកាមិត្ថេរ ជាអ្នកឆ្លើយ ព្រះសង្គីតិការាចារ្យជាព្រះអរហន្ត សុទ្ធសឹងជាតិបិដកធរចំនួន ៧០០ អង្គ ធ្វើនៅវត្តវាលុការាម ក្រុងវេសាលី ដែនវជ្ជី ក្រោមព្រះរាជូបត្ថម្ភ ព្រះបាទ កាលាសោក ជាព្រះរាជានៅក្រុងបាដលិបុត្ត (១) (បត្នា) ប្រទេសឥណ្ឌា ពុទ្ធសករាជកន្លងទៅបានចំនួន ១០០ ឆ្នាំមុនគ្រិស្តសករាជ ៣៧៧ ឆ្នាំ ។ ព្រះសង្ឃនៅចងចាំព្រះពុទ្ធវចនៈដោយមុខបាឋដដែល ។ តាមប្រពៃណីតមកនិយាយថា សង្គាយនានេះឈ្មោះទុតិយសង្គាយនា ធ្វើអស់ថិរវេលា៨ខែទើបចប់ស្រេច ។

## សង្គាយនាទីបី

កាលវេលាកន្លងទៅបានប្រមាណ ២១៨ ឆ្នាំក្រោយពុទ្ធបរិនិព្វាន មានព្រះមហាក្សត្រមួយព្រះអង្គ ព្រះនាមធម្មាសោករាជ ។ កាលនោះ មានការប្របូកប្របល់ឡើងក្នុងធម្មវិន័យព្រះពុទ្ធសាសនា ។ មានអត្ថបទខ្លះនិយាយថា ពួកអ្នកកាន់លទ្ធិព្រាហ្មណ៍ ចូលមកបួសបន្លំជាភិក្ខុ ក្នុងមណ្ឌលពុទ្ធសាសនា ដោយអាស្រ័យការបរិបូណ៌លាភសក្ការៈ ដែលកើតមានឡើងក្នុងរជ្ជកាលព្រះបាទធម្មាសោកមហារាជ ហើយពោលពាក្យអធម្មវាទីចំរូងចំរាស់ ធ្វើក្តីបរិសុទ្ធ

---

(១)–កាលនោះ ដែនវជ្ជីធ្លាក់ទៅក្រោមអំណាចដែនមគធៈ ។

ធម្មវិន័យឲ្យកើតទៅជាសទ្ធម្មបដិរូប (Mélanges)។ សេចក្តីខាងលើនេះមានសេចក្តីពិតច្រើនណាស់ ព្រោះថា ហេតុការណ៍នេះ ជាបុព្វហេតុនាំឲ្យលទ្ធិសាសនាព្រាហ្មណ៍ក្លាយទៅជាលទ្ធិសាសនាហិណ្ឌូមួយគ្រឿងទៀត ព្រមទាំងជាបុព្វហេតុឲ្យពុទ្ធសាសនាបែកទៅជានិកាយ ហើយសាបសូន្យចេញពីដែនដីឥណ្ឌា។ ក្នុងកាលនោះឯង ពុទ្ធសាសនាបែកចេញទៅជានិកាយថេរវាទ ឬ វិភជ្ជវាទ និងអាចារិយវាទ ឬមហាសាង្ឃិក តទៅ កើតប្រាកដជាពុទ្ធសាសនាលទ្ធិមហាយានមាននិកាយច្រើនរាប់មិនអស់ ។

សង្គាយនាគ្រានេះហៅ តតិយសង្គាយនា ទុកជាមហាសង្គាយនាដ៏ល្អណាស់ ព្រោះជាសង្គាយនាដើម្បីរក្សាសេចក្តីបរិសុទ្ធិធម្មវិន័យឲ្យគង់នៅតាមដើម ។ ព្រះមហាមោគ្គលិបុត្តតិស្ស ដែលព្រោសព្រះបាទធម្មាសោកមហារាជឲ្យចូលកាន់សាសន៍ពុទ្ធរតន៍ ជាអធិបតីក្នុងការសង្គាយនា មានព្រះអរហន្តជាសង្គីតិកាចារ្យចំនួន ១០០០ អង្គ ចូលប្រជុំនៅក្នុងអសោការាម ក្រុងបាដលិបុត្រដែនមគធៈ ធ្វើអស់ថិរវេលា៩ខែទើបចប់ស្រេច ក្រោមព្រះរាជូបត្ថម្ភព្រះបាទធម្មាសោកមហារាជ ។ សង្គាយនានេះ ក្នុងកាលប្រវត្តិខ្លះមិនឃើញប្រាប់កាលបរិច្ឆេទទេ[១] ប្រាប់តែកាលបរិច្ឆេទព្រះបាទធម្មាសោកឡើងសោយរាជ្យព្រះសង្ឃនៅចង់តាំងព្រះពុទ្ធវចនៈដោយមុខបាឋដដែលទៀត ។ ក្នុងសង្គាយនាទីបីនេះ ទើបមានការបញ្ជូនសមណទូតទៅប្រកាសពុទ្ធសាសនាឲ្យផុតចេញ

(១)—កាលប្រវត្តិខ្លះថា ក្នុងពុទ្ធសករាជ២៣៦ ។

ពីព្រំប្រទល់ប្រទេសឥណ្ឌា ។

នៅជម្ពូទ្វីប ប្រទេសឥណ្ឌា មានសង្គាយនាទីបួនមួយទៀត (២) ធ្វើនៅដែនកស្មីរ ក្រោមព្រះរាជូបត្ថម្ភនៃព្រះបាទកនិស្កៈ ។

## សង្គាយនាទីបួន

សង្គាយនាទីបីធ្វើស្រេចហើយ សង្ឃសុំនិមន្តព្រះមហិន្ទត្ថេរជាព្រះរាជបុត្រព្រះបាទធម្មាសោកមហារាជ ជាសមណទូតទៅប្រកាសពុទ្ធសាសនានៅលង្កាទ្វីប ។ និមន្តទៅដល់ ព្រះមហិន្ទត្ថេរបានប្រោសព្រះបាទទេវានម្បិយតិស្ស ជាព្រះមហាក្សត្រកោះលង្កា ព្រមទាំងប្រជាជននៅកោះឲ្យចូលកាន់សាសន៍ពុទ្ធតែន ។

ដើម្បីប្រតិស្ឋានពុទ្ធសាសនា ព្រះបាទទេវានម្បិយតិស្សក្រាបបង្គំទូលព្រះមហិន្ទត្ថេរ សូមធ្វើសង្គាយនាធម្មវិន័យ ។ សង្គាយនានេះមិនមានហេតុជាក្តីសៅហ្មងកើតឡើងក្នុងព្រះពុទ្ធសាសនាទេ ធ្វើដើម្បីប្រតិស្ឋានពុទ្ធសាសនានៅកោះលង្កា ។ មុនធ្វើការសង្គាយនា ព្រះបាទទេវានម្បិយតិស្សបញ្ជូនទូតឲ្យចូលទៅក្រាបបង្គំគាល់ព្រះបាទធម្មាសោកមហារាជទៅជម្ពូទ្វីប ( ប្រទេសឥណ្ឌា ) សូមនិមន្តព្រះនាងសង្ឃមិត្តាថេរី ជាព្រះរាជបុត្រីព្រះអង្គ ព្រមទាំងសាខាព្រះមហាពោធិព្រឹក្សទៅកាន់កោះលង្កាផង ត្បិតព្រះនាងអនុឡាទេវីជាព្រះអនុជថ្លៃសព្វព្រះទ័យបព្វជាជាភិក្ខុនី ។ កាលបើព្រះនាងសង្ឃមិត្តាថេរីនិមន្តដល់កោះលង្កាព្រមទាំងព្រះមហាពោធិព្រឹក្សហើយ សង្គាយនានេះក៏ចាប់ផ្តើមធ្វើឡើង ។

កាលនោះ ព្រះសង្ឃលង្កាបានសិក្សាព្រះពុទ្ធវចនៈចេះចាំស្ទាត់ច្រើនអង្គ

---

(២) ពុទ្ធសាសនាប្រទេសដទៃទៀត ពុំរាប់សង្គាយនានេះថា ជាសង្គាយនាទី៤ទេ ។

បានចូលរួមធ្វើសង្គីតិកាចារ្យ នៅវត្តថូបារាមក្នុងក្រុងអនុរាធបុរៈ ធ្វើអស់ថិរវេលាចំនួន១០ខែទើបចប់ស្រេច ក្នុងពុទ្ធសករាជ២៣៦ (មុនគ្រិស្តសករាជ ២៤១ ឆ្នាំ) សង្គាយនានេះ ទុកជាចតុត្ថសង្គាយនា ។ សង្គាយនាពប់ពីទីបួននេះតទៅ នៅប្រទេសឥណ្ឌា មិនមានកាលប្បវត្តិត្រាទុកមកទេ មានតែនៅក្នុងកាលប្បវត្តិកោះលង្កា គឺគម្ពីរមហាវង្សនិងទីបវង្ស ។

## សង្គាយនាទីប្រាំ

ក្នុងកាលប្បវត្តិនៅកោះលង្កា មានសេចក្តីថា ព្រះបាទវដ្តគាមិនីអភ័យព្រះមហាក្សត្រកោះលង្កា ទ្រង់កសាងវត្តមួយនៅក្នុងក្រុងអនុរាធបុរៈ ហើយឲ្យឈ្មោះថា "អភយគិរីវិហារ" ប្រគេនមហាថេរព្រះនាមតិស្ស(១)។ ព្រះមហាថេរអង្គនេះ កាន់តាមលទ្ធិវជ្ជីបុត្តកភិក្ខុពីធម្មវិន័យ ជាហេតុនាំឲ្យមានការទំនាស់ដល់ព្រះសង្ឃនៅវត្តមហាវិហារ ។ ការមិនចុះសម្រុងគ្នានេះហើយដែលជាហេតុនាំឲ្យកើតសង្គាយនាទីប្រាំឡើង ជាការសង្គាយនាសំខាន់ នាំឲ្យចារឹកព្រះពុទ្ធវចនៈឡើងកាន់ស្លឹករឹត ជាលាយលក្ខណ៍អក្សរមុនដំបូងបង្អស់ក្នុងប្រវត្តិពុទ្ធសាសនា ។

សង្គាយនានេះ ទុកជាបញ្ចមសង្គាយនា សង្គាយនាចារឹកពុទ្ធវចនៈជាលាយលក្ខណ៍អក្សរនៅក្នុងវត្តមហាវិហារ ព្រះពុទ្ធត្ថេរជាប្រធាន ជាអ្នកសួរ

(១)–ព្រះមហាថេរតិស្សអង្គនេះ អានតាមបញ្ញត្តិមួយទៀតថា ធម្មរុចិយៈ ជាអ្នកតែងគម្ពីរមួយឈ្មោះថាវិមុត្តិមគ្គ ជាគម្ពីរប្រហាក់ប្រហែលនឹងគម្ពីរវិសុទ្ធិមគ្គ ជាស្នាដៃព្រះពុទ្ធឃោសាចារ្យ ព្រឹត្តិការណ៍បែបនេះ កើតមានខនៅឯបទ្វីបអាស៊ីភាគអគ្នេយ៍នេះដែរ គឺគម្ពីរសារត្ថសង្គហៈ ជាស្នាដៃព្រះនន្ទាចារ្យប្រហាក់ប្រហែលនឹងគម្ពីរទីបនីអដ្ឋកថាមង្គលសូត្រ ជាស្នាដៃព្រះសុមង្គលាចារ្យ ។

ព្រះតិស្សត្ថេរជាអ្នកធ្វើយ ក្រោមព្រះរាជូបត្ថម្ភព្រះបាទវដ្តគាមិនីអភ័យ ព្រះមហាក្សត្រកោះលង្កា ធ្វើអស់ចិរវេលាមួយឆ្នាំចប់ស្រេច ក្នុងពុទ្ធសករាជ ៥២០ (មុនគ្រិស្តសករាជ៦៤ឆ្នាំ) ។

ចំណេរកាលតមក មានការសង្គាយនាយកចប់ផ្តួមកទៀត នៅកោះលង្កា នៅប្រទេសភូមា នៅប្រទេសសៀម ។ នៅប្រទេសភូមា មានការសង្គាយនា ហើយចារឹកព្រះពុទ្ធវចនៈជាលាយលក្ខណ៍អក្សរជាក់លើផែនថ្មកែវច្រើនរយផ្ទាំង នៅក្រុងមណ្ឌលេ នៅក្រុងប៉េគូ (ហង្សាវតី) នៅជាទង "ស្រុកមាស" (១) ។

## សង្គាយនាខ្មែរ

នៅប្រទេសកម្ពុជាយើង តាំងពីព្រេងនាយដែលមានពុទ្ធសាសនាមកប្រតិស្ឋាននៅលើទឹកដីយើង មិនមានប្រវត្តិស្តីទុកថា បានធ្វើសង្គាយនាព្រះត្រៃបិដកទេ ។ ក្នុងរាជ្យព្រះបាទសម្តេចព្រះស៊ីសុវត្ថិមុនីវង្សព្រះបរមខត្តិយកោដ្ឋ ទើបមានការសង្គាយនាព្រះត្រៃបិដកជាពុទ្ធវចនៈនេះឡើងដំបូង ។ ការសង្គាយ-នាគ្រានេះ ស៊ីវេលាបីរាជ្យ គឺរាជ្យព្រះបាទសម្តេចព្រះស៊ីវត្ថិមុនីវង្ស រាជ្យព្រះបាទសម្តេចព្រះនរោត្តមសីហនុវរ្ម័ន និងរាជ្យព្រះបាទសម្តេច ព្រះនរោត្តមសុរាម្រិត គឺតាំងពីពុទ្ធសករាជ ២៤៧៣ (គ.ស.១៩២៩) ដល់ពុទ្ធសក-រាជ២៥១៣ (១៩៦៩) ស៊ីវេលាអស់៤០ឆ្នាំគត់ ។ សង្គាយនានៅប្រទេសកម្ពុជានេះ លោកទុកជាឆដ្ឋសង្គាយនា ឬជាឧត្តមសង្គាយនា "សង្គាយនាដ៏

១ — ប្រពៃណីផងជាតិមនថា ទីនេះហើយជា សុវណ្ណភូមិ ។

ឧត្តម " ព្រោះមានក្តីពិសេសមួយ ដែលមិនដែលកើតមាននៅក្នុងប្រវត្តិពុទ្ធសាសនា គឺការប្រែព្រះពុទ្ធវចនៈជាភាសាបាលី ដែលមានរាប់ពាន់ឆ្នាំមកហើយ ទៅជាភាសាជាតិខ្មែរ គឺទំព័រម្ខាងជាបាលី ម្ខាងទៀតជាខ្មែរ ។ នេះជាការពិសេសលើសសង្គាយនាទាំងពួងដែលមានមកហើយ ។ ប្រទេសកាន់ពុទ្ធសាសនាក្តី មិនកាន់ព្រះពុទ្ធសាសនាក្តី កាលបើបានដឹងកិច្ចការដ៏ពិសេសនេះហើយ តែងតែកោតស្ញើចក្រៃលែង ។

## ខ្លឹមព្រះធម៌

ការសង្គាយនាជាភាសាបាលីដោយមុខបាឋក្តី ចារឹកជាលាយលក្ខណ៍អក្សរក្តី ប្រែជាភាសាជាតិក្តី សុទ្ធតែជាការប្រសើរបំផុត ឈ្មោះថា ការរក្សាព្រះពុទ្ធវចនៈទុកដើម្បីឲ្យគង់នៅបរិសុទ្ធដដែល ឈ្មោះថា ញុំាងពុទ្ធសាសនាឲ្យឋិតថេរចីរកាលអង្វែងតទៅ ឈ្មោះថា សាងព្រះសម្ពុទ្ធគ្រប់កាលទាំងពួង បើព្រះពុទ្ធវចនៈនេះ គង់វង្សនៅដរាបណា ឈ្មោះថាព្រះសម្ពុទ្ធគង់ធរមាននៅដរាបនោះ សមដូចពុទ្ធភាសិតថា :

វក្កលិ ! អ្នកណាឃើញធម៌តថាគត អ្នកនោះឈ្មោះថាឃើញរូបតថាគត អ្នកណាឃើញរូបតថាគត អ្នកនោះឈ្មោះថាឃើញធម៌តថាគតដែរ ។

ការបានធ្វើសក្ការយនាព្រះពុទ្ធវចនៈតាំងពីដើមទី ជាការប្រសើរបំផុត ។ ការដ៏ប្រសើរបែបនេះ មិនមានក្នុងពាហិរសាសនាទេ ។ ពុទ្ធសាសនិកជនសប្បាយចិត្តណាស់ កាលបើបានឃើញសាសនារបស់ខ្លួនមានការដ៏ប្រសើរ សប្បាយចិត្តណាស់ កាលបើបានឃើញថា ព្រះសម្ពុទ្ធជាបរមគ្រូរបស់ខ្លួននៅជាមួយខ្លួនគ្រប់កាលវេលា និងបានដឹកដៃនាំខ្លួនដែលខ្វាក់ឲ្យដើរត្រង់តាមមាគ៌ាប្រសើរទៅរកក្ដីសុខពិត ដោះស្រាយប្រស្នាជីវិតរបស់ខ្លួនឲ្យដល់អវសាន មិនមានកពថ្មីតទៅទៀត សមដូចពុទ្ធភាសិតថា :

«អានន្ទ អ្នកណាមួយ ភិក្ខុក្ដី ភិក្ខុនីក្ដី ឧបាសកក្ដី ឧបាសិកាក្ដី ប្រតិបត្តិធម៌ត្រឹមត្រូវតាមធម៌ ប្រតិបត្តិដោយភក្ដីភាព ប្រតិបត្តិតាមគន្លងធម៌ អ្នកនោះឈ្មោះថា បូជាតថាគត ធ្វើសក្ការៈ គោរពរាប់អានដោយការបូជាដ៏ប្រសើរបំផុត» ។

សេចក្ដីក្នុងបច្ឆិមពុទ្ធវចនៈនេះ ប្រែថា “បើអ្នកណាមួយប្រតិបត្តិតាមពុទ្ធវចនៈដោយត្រឹមត្រូវ អ្នកនោះនឹងបានឃើញធម៌ (លុះនិព្វាន) ឥតសង្ស័យឡើយ” ព្រោះថា អត្តាធីនភាព (Emancipation) មនុស្សលោកថិតនៅក្នុងអភិសម័យ (Réalisation) ។ បំណុចនេះ សំខាន់បំផុត ពាហិរសាសនាធ្វើឲ្យសម្រេចដូចពុំបានឡើយ ។

ព្រះត្រៃបិដកជាពុទ្ធវចនៈនេះ អ្នកប្រាជ្ញក្នុងបច្ចុប្បន្នកាល គោតស្ងើចក្រៃលែង គោតស្ងើចថា ពុទ្ធវចនៈនេះប្រសើរបំផុត បើជាសីលធម៌ ជា

សីលធម៌ដ៏លើស, បើជាវិទ្យាសាស្ត្រ ជាវិទ្យាសាស្ត្រដ៏លើស, បើជាទស្សនវិជ្ជា ជាទស្សនវិជ្ជាដ៏លើស, បើជាសាសនា ជាសាសនាដ៏លើស ។ *ទស្សនវិទូ អ្នកវិទ្យាសាស្ត្រ អ្នកសីលធម៌ ដែលបានសិក្សាព្រះពុទ្ធវចនៈនេះហើយ ពោលថា “ការរកឃើញរបស់យើងសព្វថ្ងៃនេះ ព្រះសម្ពុទ្ធរកឃើញរួចហើយ ប្រមាណជា២៥១៣ឆ្នាំ មុនយើងទៅទៀត” ។*

*អ្នកប្រាជ្ញស្រាវជ្រាវបុរាណវត្ថុនៅប្រទេសឥណ្ឌា ដែលបានធ្វើការគាស់កកាយពុទ្ធស្ថាន មានសំវេជនីយដ្ឋានជាដើម ពោលថា “ទីឋានទាំងនេះ បើជាទីឋានមនុស្សសាមញ្ញដូចយើងគ្រប់គ្នានុះ មិនមានប្រយោជន៍អ្វីនឹងមកធ្វើការគាស់កកាយរក អស់ប្រាក់កាស អស់កម្លាំងទេ ព្រោះទីឋានទាំងនេះ សព្វថ្ងៃ ទៅជាទីឋានគួរឲ្យកើតសង្វេគបំផុត កាលដើមធ្លាប់រុងរឿង ឥឡូវទៅជាទីរហោឋាន គេបោះបង់ចោល ។ តែការនេះ មិនមែនដូច្នោះឡើយ” ព្រះសម្ពុទ្ធនេះ ជាមនុស្សប្លែកណាស់ ជាអច្ឆរិយបុគ្គល មិនមានពីរក្នុងលោកនេះទេ មើលពុទ្ធវចនៈដោយហ្មត់ចត់ ឃើញថា មិនមានលោកណា ដែលចេះនិយាយពិតប្រាកដដូចព្រះអង្គ* (Objectivisme) ។ *ពុទ្ធវចនៈ* “ជាមេសីលធម៌ ជាមេវិទ្យាសាស្ត្រ ជាមេទស្សនវិជ្ជា ជាមេសេដ្ឋកិច្ច ។ល។ សម្រាប់មនុស្សលោក” ។ *ការប្រើកម្លាំងទ្រព្យ កម្លាំងកាយ ក្នុងការ*

ការកែពុទ្ធស្ថាននេះ ជាការចំណេញ មានប្រយោជន៍ឥតគណនា ឈ្មោះថា

“ធ្វើអង្គព្រះសម្ពុទ្ធឲ្យគង់ធរមានឡើងវិញ ” ។

ក្នុងពិធីបុណ្យសម្ពោធន៍ពុទ្ធសាសនា ២៥០០ នៅប្រទេសឥណ្ឌា លោកបណ្ឌិតនេរុ បានបំណាយថវិកាជាតិ រៀបចំពុទ្ធស្ថានទាំងឡាយឲ្យបានជាទីរមណីយដ្ឋានឡើងវិញ ។ ប្រជាជនហិណ្ឌូ បានស្តីបន្ទោសលោកយ៉ាងសន្ធឹកបន្ទោសថា “ ម្តេចឡើយ ក៏បំណាយថវិកាជាតិជារបស់ហិណ្ឌូ ទៅតុបតែងពុទ្ធស្ថានដែលមិនមែនជាហិណ្ឌូទៅវិញ ” ។

លោកបណ្ឌិតនេរុ កាលនោះ លោកឆ្លើយតបវិញថា “ ចុះព្រះពុទ្ធ ជាកូនទៅអ្នកណា ? ជាជនជាតិអ្វី ? សព្វថ្ងៃក្នុងពិភពលោកទាំងមូលនេះ លទ្ធិហិណ្ឌូ (Hindouisme)របស់អ្នក ក្រៅពីប្រជាជនហិណ្ឌូ តើមាននរណាទទួលស្គាល់ដែរឬទេ ? ឯព្រះពុទ្ធ មានគេទទួលស្គាល់ពេញសកលលោក ។ ការបំណាយថវិកាជាតិ ដើម្បីព្រះពុទ្ធ

## ជាការបំណាយដ៏ប្រសើរ ជាការបូជាដ៏ប្រសើរបំផុត

គួរអស្ចារ្យថ្លៃកណាស់ ! អង្គព្រះសម្ពុទ្ធជាមនុស្សដូចយើងគ្រប់គ្នា តែទ្រង់ជាសព្វញ្ញូ ត្រាស់ទេសនាត្រឹមត្រូវ ពុទ្ធវចនៈទាំងអស់ជាសច្ចធម៌ ។

ទឹកដីលោកយើងនេះ កើតមានឡើងកប់ហ៊ឺនឆ្នាំកន្លងទៅហើយ តើមានមនុស្សលោកប៉ុន្មាននាក់ ដែលចេះនិយាយត្រូវប្រាកដដូចអង្គព្រះសម្ពុទ្ធ ក្នុង

ប្រវត្តិសាស្ត្រលោកយើងនេះ? ។ សំនួរនេះ មិនបានទទួលចម្លើយល្អទេ ។ ចំណុចនេះ មុខគួរឲ្យកោតសើចក្រៃលែងចំពោះព្រះពុទ្ធវចនៈដែលជនជាតិខ្មែរយើងគ្រប់គ្នាស្គាល់ថា " ព្រះត្រៃបិដក " នេះ ។ អ្នកប្រាជ្ញច្រើននាក់បានសិក្សាពុទ្ធវចនៈ សិក្សាដោយហ្មត់ចត់ អ្នកប្រាជ្ញខ្លះ ពោលថា " តាមពុទ្ធវចនៈ (Pensée Bouddhique) នេះ ព្រះពុទ្ធមិនមែនជា « អ្នកប្រាជ្ញកណ្តាលហ្វូងមនុស្សល្ងង់ទេ ទ្រង់ជាអ្នកប្រាជ្ញកណ្តាលហ្វូងអ្នកប្រាជ្ញខ្ពស់ទាំងឡាយ» សម័យឧបនិស័ទ ខាងដើមសម័យពុទ្ធកាល មានអ្នកប្រាជ្ញច្រើននាក់ណាស់( សុទ្ធសឹងជាអ្នកគិតប្រសើរ =Grands Penseurs) ។

ក្នុងប្រវត្តិសាស្ត្រលោកនេះ លទ្ធិសាសនាទាំងអស់ សុទ្ធតែជាពាហិរ-សាសនា (Religions) ។ វចនៈគឺពាក្យពេចន៍របស់មេសាសនាទាំងនោះគឺ មេគណាចារ្យព្រាហ្មណ៍ គ្រិស្ត មោហម័ត ឡៅត្សឺ ខុងត្សឺ សោពេកាស្ត្រ ទាំងអស់នេះ សុទ្ធតែជាវាទៈ (Doctrine ) , ជាទិដ្ឋិ( Dogme) , ជាអន្តរវាទ ( Doctrine ésotérique ), ជាពាហិរវាទ ( Doctrine exotérique ), ទីបំផុតជាអាចរិយមុដ្ឋិ " កណ្តាប់ដៃអាចារ្យ =អាទិទេព (Dieu ) ពោលគឺស្រេចហើយតែមេសាសនាថា " ។

ធម្មវិន័យព្រះសម្ពុទ្ធប្រកបដោយហេតុផល មិនមានក្នុង មិនមានក្រៅទេ ក្នុងមហាបរិនិព្វានសូត្រ ព្រះអង្គទ្រង់ត្រាស់ទុកថា :

“អានន្ទ! ធម្មវិន័យតថាគតសំដែងហើយ មិនមានក្នុង មិនមានក្រៅទេ = ទេសិតោ អានន្ទ មយា ធម្មោ អនន្តរំ អពាហិរំ ” ។ ពុទ្ធវចនៈបញ្ជាក់ច្បាស់ថា “ ធម៌ព្រះអង្គ មិនមែនជាអន្តរវាទ ( Doctrine ésotérique ) ទេ, មិនមែនជា ពាហិរវាទ ( Doctrine exotérique ) ទេ ។ ទីបំផុត ធម៌អង្គព្រះសម្ពុទ្ធមិនមែនជា អាចរិយមុដ្ឋិ =កណ្តាប់ដៃមេសាសនា (Dieu) ទេ ។ ក្នុងប្រវត្តិសាសនាសាកលលោកមិនដែលមានមេសាសនាណា អាចពោលដូចអង្គព្រះសម្ពុទ្ធដូច្នេះបានឡើយ ។

ដើម្បីបញ្ចប់ សូមលើកយកសំដីលោក រីស ដេវិត ( Rhys Dawids) មកពោល លោកនេះបានសិក្សាពុទ្ធវចនៈប្រសើរបំផុត ពេញចិត្តចំពោះពុទ្ធវចនៈបំផុត លោកបានសិក្សាហើយបានបង្កើតសមាគមមួយឈ្មោះ “ បាលីតិក្សូសៃយេទី ( Pali Text Society ) នៅក្រុងឡុង បានបោះពុម្ពព្រះត្រៃ-បិដកជាពុទ្ធវចនៈផ្សាយទូទៅក្នុងសកលលោក ។ អ្នកប្រាជ្ញទូទៅស្គាល់សមាគមនេះ ។ លោកបញ្ចេញយោបល់របស់លោកចំពោះពុទ្ធវចនៈនេះថា :

“ ពាក្យសំដីមេសាសនាទាំងអស់ ទាំងតូច ទាំងធំ មិនមានមេសាសនាណាម្នាក់អាចប្រមូលគោលធម្មបដិបត្តិ ដើម្បីកសាងមនុស្សលោកឲ្យប្រសើរស្មើ ដោយអដ្ឋង្គិកមគ្គរបស់ព្រះសម្ពុទ្ធបានឡើយ ។ ព្រះសម្ពុទ្ធចេះប្រមូលគោលប្រតិបត្តិសម្រាប់ទូន្មានមនុស្សយ៉ាងខ្លីត្រឹមតែ ៨ មាត់ ។ ធម៌នេះ បើមនុស្ស

បានយកមកប្រតិបត្តិហ្មត់ចត់ ( ធម្មានុធម្មបដិបត្តិ, អនុធម្មចារ ) មនុស្សនឹងបានសម្រេចផលសមតាមប្រាថ្នា ឥតសង្ស័យឡើយ ។ ខ្លួនខ្ញុំដែលបានឃើញធម្មវិន័យប្រសើររបស់ព្រះអង្គយ៉ាងនេះហើយ ខ្ញុំហ៊ានប្រកាសខ្លួនខ្ញុំនៅកណ្តាលប្រជាជនអង់គ្លេសថា : « ខ្ញុំជាពុទ្ធសាសនិក » ពេញទ្រូងមាត់ឥតកោតញញើតឡើយ ។

ដូច្នេះ ព្រះត្រៃបិដកជាពុទ្ធវចនៈ មានតម្លៃថ្លៃផុតគណនានឹងរាប់បាន សម្រាប់កសាងមនុស្សលោក ឲ្យមានគុណសម្បត្តិខ្ពង់ខ្ពស់ មានអរិយធម៌ខ្ពង់ខ្ពស់ ។ ប្រស្នាទុក្ខដែលមនុស្សលោកខំដោះស្រាយយូរអង្វែងហើយ មិនទាន់បានសម្រេចផលនោះ បានសម្រេចដោយពុទ្ធវចនៈនេះឯង ។ ពុទ្ធវចនៈ ជាមធ្យោបាយប្រសើរវិសេស ឬ ជាច្រកចេញឲ្យផុតពីទុក្ខមិនមានសេសសល់ឡើយ ។

វិទ្យាសាស្ត្រប្រសើរណាស់ដែរ ដើរផ្លូវស្របតាមពុទ្ធសាសនា តែជាផ្លូវវែង ( បបញ្ចធម៌ ) មិនមានទីបំផុត ជាដំណើរលោកិយវិស័យ ។ សព្វថ្ងៃមនុស្សលោកពេញចិត្តចំពោះវិទ្យាសាស្ត្រ តែវិជ្ជានេះ ដោះស្រាយទុក្ខមិនអស់ដើងទេ ។ ប្រស្នាសុខពីរប្រការគឺ អាមិសសុខ និងនិរាមិសសុខ វិទ្យាសាស្ត្រដោះស្រាយទុក្ខបានខ្លះ ចំពោះតែអាមិសសុខ ឯពុទ្ធសាសនា

ដោះស្រាយទុក្ខបានអស់ជើង គឺបានសុខទាំងពីរប្រការខាងលើនេះឯង ។

ផ្លូវលោក ផ្លូវធម៌ មនុស្សលោកបានត្រាយផ្លូវទុកមកស្រេចហើយ តែការដោះស្រាយនូវប្រស្នាទុក្ខស្រេចហើយតែមនុស្សម្នាក់ៗដើរទេ ។ មាគ៌ាត្រង់ទៅដល់គោលបំណងមានគ្រប់ តែបើមនុស្សមិនដើរតាម ផ្លូវក៏ទុកជាឥតប្រយោជន៍ ទឹកសំរាប់លាងគ្រឿងប្រលាក់ (បាប)ឲ្យស្អាតមាន តែបើគេមិនត្រូវការទឹកលាង នឹងថា ទោសទឹកក៏ឥតអង្គឹមានដែរ ។ ដាវមុត តែបើមុតនៅតែក្នុងស្រោម ក៏មិនមានប្រយោជន៍អ្វីដែរ ។ ព្រះត្រៃបិដកជាពុទ្ធវចនៈ ជាព្រះពុទ្ធមួយព្រះអង្គដែលគង់ធរមាននៅ តែបើមិនមានអ្នកដើរតាម ព្រះពុទ្ធគង់នៅដោយឡែក មនុស្ស សត្វ ទេវតា មារ ព្រហ្ម អង្គុយនៅដោយឡែក ។

ប្រមូលចងក្រងដោយគណៈកម្មាធិការជាតិនៃខេមរយានកម្ម

*

* *

រោងពុម្ព មិត្តភាព
កម្ពុជា-ជប៉ុន

តម្លៃ : ៧០០ រៀល